Sovereignty (អធិបតេយ្យភាព)

អធិបតេយ្យភាព មានពីរសមាសភាគៈ ខាងក្នុង និងខាងក្រៅ ដែលមានទំនាក់ទំនងគ្នា។ ក្នុងរដ្ឋមានអំណាចអធិបតេយ្យភាព ដែលអាចធ្វើច្បាប់ និងមិនតម្រូវឲ្យរដ្ឋដទៃទៀត ត្រូវទទួលស្គាល់។ អំណាចនេះ មិនតម្រូវឲ្យគោរពអាជ្ញាធរក្រៅប្រទេសទេ។ ផ្នែកខាងក្រៅនៃអធិបតេយ្យភាព សំដៅលើ ឯករាជ្យភាព។

អំណាចនេះ មានរហូតដល់សតវត្សទី១៦ ដែលពេលនោះ អនុលោមតាមទ្រឹស្តីច្បាប់ធម្មជាតិ។ ក្រោយមកក្នុងសតវត្សទី១៨ គំនិតនៃរដ្ឋ (nation state) កើតមានឡើង អធិបតេយ្យភាពបានចាប់ផ្តើមមានកម្រិត។ គំនិតនៃវត្តមាននៃសហអត្ថិភាពនៃរដ្ឋ (law of co-existence) បានប្តូរជាច្បាប់សហការ (law of cooperation) ហើយទស្សនទាននៃសាមគ្គីភាព (solidarity) ព្រមទាំងសហគមអន្តរជាតិ (international community) ក៏ចាប់មានឡើង។

ក្រោយឆ្នាំ១៩៤៥ ទ្រឹស្តីអធិបតេយ្យភាព កាន់តែមានការវិវត្ត។ ក្នុងន័យថា មានការចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ អំពីអធិបតេយ្យស្មើគ្នា និងត្រូវបានបញ្ជាក់បន្ថែមក្នុង Friendly Relations Declaration ឆ្នាំ១៩៧០។ អធិបតេយ្យភាព តម្រូវឲ្យមានសិទ្ធិនិងកាតព្វកិច្ចដូចគ្នា មានឯករាជ្យភាព មានបុគ្គលិកលក្ខណៈគតិយុត្តអន្តរជាតិ (international legal personality) និងសមត្ថភាពក្នុងការចូលរួមក្នុងឆាកអន្តរជាតិ មានយុត្តាធិការ និងអាចដាក់ពាក្យបណ្តឹងប្រឆាំងនឹងរដ្ឋដែលបំពាន។ អធិបតេយ្យភាព ក៏តម្រូវឲ្យមានការការពារដោយច្បាប់អន្តរជាតិ ដូចជា ការមិនអន្តរាគមពីខាងក្រៅ (intervention) មានកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការការពារ ប្រជាពលរដ្ឋខ្លួន (responsibility to protect)។

រដ្ឋមានអធិបតេយ្យភាព អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ត្រូវគោរពគោលការណ៍សន្តិភាពនិយម ហើយសិទ្ធិធ្វើសង្គ្រាម បានរួមតូច ប្រសិនប្រៀបធៀបនឹងសតវត្សមុន ដោយអនុញ្ញាតតែសិទ្ធិការពារខ្លួន (self-defense) ឬ សន្តិសុខរួមគ្នា (collective security) ក្រោមឆ័ត្រ អង្គការសហប្រជាជាតិ (UN Concise Encyclopedia, 2010, pp. 663-667)។

**<u>ខ្លឹមសារបន្ថែម</u>**៖ អធិបតេយ្យភាព មានចំណងទាក់ទំនងនឹងអភ័យឯកសិទ្ធិ (immunity) និងយុត្តការធិការក្នុងស្រុក (domestic affairs)។ ដោយសារ អធិបតេយ្យភាពលែងមានលក្ខណៈដាច់ខាតដោយសារឥទ្ធិពលនៃការពឹងអាស្រ័យគ្នារវាងរដ្ឋនិងរដ្ឋ (interdependent) ឬការចូលជាសមាជិក

ឬភាគីនៃកិច្ចព្រមព្រៀង ដែលរដ្ឋទទួលយកកាតព្វកិច្ចខ្លះ តាមរយៈនេះ ដោយប្រយោល អធិបតេយ្យភាពត្រូវបានកម្រិតខ្លះ អភ័យឯកសិទ្ធិក៏ត្រូវបានកម្រិតដែរ។ ជាក់ស្តែង រដ្ឋ ឬមេដឹកនាំរដ្ឋ មិនមានអភ័យឯកសិទ្ធិរួចពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ ប្រសិនបើប្រព្រឹត្តបទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ។ ស្រដៀងគ្នាដែរ គឺបញ្ហាឬយុត្តាធិការក្នុងស្រុក។ ពាក្យ “domestic affairs” ត្រូវបានបកស្រាយយ៉ាងចង្អៀត។